# សិលាចារឹករកឃើញថ្មីនៅទួលប្រាសាទកជ្រៃ ខេត្តបន្ទាយមានជ័យ

ទួលប្រាសាទកជ្រៃ មានទីតាំងស្ថិតនៅភូមិព្រះអណ្តូង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ និងមានចម្ងាយ ៣,៧ គីឡូម៉ែត្រ ប៉ែកឦសានប្រាសាទភ្នំកូនខ្វែង។ បច្ចុប្បន្នប្រាសាទនេះបានបាក់បែកនៅសល់តែគ្រឹះប៉ុណ្ណោះ ប៉ុន្តែមាននៅសល់វត្ថុសិល្បៈធ្វើអំពីថ្មភក់ជាច្រើន។ គួរឱ្យចាប់អារម្មណ៍ នៅខែមេសា ឆ្នាំ២០២៦ លោក ចាន់ អឿន អនុប្រធានការិយាល័យបេតិកភណ្ឌ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ បានប្រទះឃើញសិលាចារឹកថ្មីមួយដែលចារឹកនៅលើជើងទម្រព្រះប្រតិមា ក្នុងអំឡុងពេលចុះពិនិត្យ និងផ្ទៀងផ្ទាត់ស្ថានភាពបុរាណដ្ឋាននេះ ដើម្បីធ្វើបច្ចុប្បន្នភាពសាជាថ្មី។ បន្ទាប់ពីបានរកឃើញ លោក ចាន់ អឿន និងលោក គី បញ្ញារិទ្ធិ អនុប្រធានការិយាល័យសារមន្ទីរ បានរាយការណ៍ព័ត៌មាននេះមកកាន់ខ្ញុំ ហើយខ្ញុំបាទបានចុះទៅធ្វើសំណៅផ្ទិតដល់ទីតាំងផ្ទាល់នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៦។ តើសិលាចារឹករកឃើញថ្មីនៅទួលប្រាសាទកជ្រៃ ខេត្តបន្ទាយមានជ័យ មានខ្លឹមសារ និងអត្ថន័យដូចម្តេចខ្លះ?

ដោយសារតែជើងទម្រថ្មភក់នេះបាក់បែកជាបំណែកទៅហើយ អក្សរចារឹកបានបាក់បែកជាបំណែក និងខ្លះទៀតស្ថិតនៅជាប់ជាមួយជើងទម្រនៅឡើយ។ ផ្នែកខ្លះចារឹកនៅលើគែមខាងលើនៃទម្រ (ក្បាល) និងផ្នែកខ្លះទៀតចារឹកនៅលើក្បាច់បន្ទះត្រង់នៅចំពាក់កណ្តាល (តួ)។ នៅគែមខាងលើ (ក្បាលជើងទម្រ) ចារឹកជាភាសាខ្មែរបុរាណ ក្នុងទម្រង់ជាអក្សរជ្រៀងនៃស.វ.ទី១២ ដោយមានអក្សរចំនួន ២ ផ្នែក ហើយក្នុងនោះផ្នែកទី១មានចំនួន ២ បន្ទាត់ និងផ្នែកទី២មានចំនួន ១ បន្ទាត់។ ក្នុងចំណោមអក្សរទាំងនោះ មានផ្នែកខ្លះរលុបបាត់ដោយអន្ទើ នាំឱ្យពិបាកអាន។ រីឯនៅក្បាច់បន្ទះត្រង់ចំពាក់កណ្តាលទម្រ (តួ) ចារឹកអក្សរចំនួន ២ ផ្នែក ពោល គឺផ្នែកទី១ចារជាភាសាសំស្ក្រឹតមានចំនួន ២ បន្ទាត់ (ស្មើ ១ ស្លោក) និងផ្នែកទី២ចារជាភាសាខ្មែរចំនួន ១ បន្ទាត់។

ដោយសារតែអក្សរចារឹកនៅគែមខាងលើរលុបបាត់ដោយអន្ទើ ផ្នែកខាងលើដែលនៅសេសសល់ គឺគ្រាន់តែឱ្យយើងដឹងអំពីតង្វាយជាមូលនិធិសម្រាប់ប្រាសាទតែប៉ុណ្ណោះ ព្រោះពាក្យនៅសល់មានដូចជា ភូមិវៅ, ស្រេវ្នុរ (ស្រែទួល) ជាដើម។ រីឯផ្នែកខាងក្រោម រៀបរាប់អំពីការប្រារព្ធពិធីទក្សិណោទក (ប្រួចទឹក ឬទឹកទក្សិណោទក) ថ្វាយដល់ព្រះប្រតិមា។

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*ចំណែក អក្សរនៅផ្នែកកណ្តាលដែលចារឹកជាភាសាសំស្ក្រឹតនិងខ្មែរនោះ គឺនាំឱ្យយើងដឹងថា ដើងទម្រ ឬបល្ល័ង្កនេះ គឺជាបល្ល័ង្កសម្រាប់តម្កល់ពុទ្ធបដិមា (ទេពក្នុងព្រះពុទ្ធសាសនា) ព្រោះបានបង្ហាញថា ព្រះប្រតិមា **"ព្រះមុនិន្ទ្រ"** (ព្រះនាមរបស់ព្រះពុទ្ធ) មហាត្មា (មានខ្លួន ឬអាត្ម័នដ៏មហាសាល) ទ្រង់មានព្រះកិត្តិ៍នាម ឬពិសិដ្ឋ ហើយទ្រង់គង់នៅក្រោមពោធិមណ្ឌល។ បន្ថែមពីនេះ គេបញ្ជាក់ថា ពុទ្ធប្រតិមានេះបានស្ថាបនាឡើងដោយអ្នកដែលមិនជាប់ជំពាក់នឹងផលប្រយោជន៍ខ្លួនឯង មាននាមថា **"វសុទេវ"** រួមជាមួយសប្បុរសជនជាច្រើននាក់ទៀត។ ដូច្នេះហើយ ខ្លឹមសារសិលាចារឹកនៅគែមខាងលើ (ផ្នែកខាងក្រោម) ដែលរៀបរាប់អំពីពិធីទក្សិណោទក (ពិធីច្រូចទឹក) គឺប្រហែលជាធ្វើទៅលើពុទ្ធប្រតិមានេះឯង (ព្រះមុនិន្ទ្រ)។*

**អត្ថបទចារឹក**

**ក. គែមខាងលើ** (**ផ្នែកក្បាលនៃជើងទម្រ**)

**ជ្រុងទី១** (**ផ្នែកខាងលើ**)

១. ............ប្រំបិយ ....................

២. បង្សំ នោះ ភូមិ ពោ ប្ញ មាន ស្រេ វ្នុ

**ជ្រុងទី២** (**ផ្នែកខាងក្រោម**)

១. វាម ទក្សិណោទក ត ព្រះ

**ខ. ផ្នែកកណ្តាល** (**ក្បាច់បន្ទះត្រង់**) (**ផ្នែកតួនៃជើងទម្រ**)

**ជ្រុងទី១** (**កំណាព្យបែប "ឧបជាតិឆន្ទ"**)

១. យោវោធិមូលាខ្យតតិប្រសិទ្ធេ ជាមេមុនិន្ទ្រប្រតិមា មហាត្មា
អតិប្ទិវត្សាច៌និរីហាវិទ្ទ ជូនេន សាទ៌្ធំ វសុទេវនាម្នា។

**ជ្រុងទី២**

១. ........កាម្រតេង្គកត អពសាន ៙

**បំណកប្រែ**

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

## ក. គែមខាងលើ (ផ្នែកក្បាលនៃជើងទម្រ)

### ជ្រុងទី១ (ផ្នែកខាងលើ)

*(បន្ទាត់ទី១ -២) ......ប្រាំបី .....ផ្សំ នោះ ដីភូមិវ៉ា (ពោ) មាន ដីស្រែ វ្នុ (ទួល)*

### ជ្រុងទី២ (ផ្នែកខាងក្រោម)

*(បន្ទាត់ទី១) វាម (ខាងឆ្វេង) ទក្សិណោទក (ប្រូចទឹកទក្សិណោទក) ថ្វាយចំពោះព្រះ (ប្រតិមា)*

## ខ. ផ្នែកកណ្ដាល (ក្បាច់បន្ទះត្រង់) (ផ្នែកតួនៃជើងទម្រ)

### ជ្រុងទី១ (កំណាព្យបែប "ឧបជាតិឆន្ទ")

*(**ស្លោកទី១**) ព្រះមហាត្ម័ន (មានខ្លួនឬអាត្ម័នដ៏មហាសាល) អង្គណា ទ្រង់បានត្រាស់ដឹងហើយ ត្រង់ទីស្ថានឈ្មោះថា ពោធិមូល (ក្រោមដើមពោធិព្រឹក្ស), **ព្រះមុនីន្ទ្រប្រតិមា** (ព្រះប្រតិមានៃព្រះពុទ្ធ) អង្គនោះ បានរួមគ្នាជាមួយនិងសប្បុរសជន និងអ្នកប្រាជ្ញម្នាក់ទៀតមាននាមថា "**វសុទេវ**" ដែលមិនមានសេចក្ដីលោភលន់ក្នុងអត្ថប្រយោជន៍ផ្ទាល់ខ្លួន បានតម្កល់ទុកហើយ នាទីស្ថានដ៏ពិសិដ្ឋនេះ។*

### ជ្រុងទី២

*(បន្ទាត់ទី១) ........កម្រតេង្ជគត អពសាន = កម្រតេង ជគត អពសាន = អវសាន (ខាងចុង)។*

*ជារួមមក សិលាចារឹករកឃើញថ្មីនៅប្រាសាទកជ្រៃ ខេត្តបន្ទាយមានជ័យ គឺជាប្រភពពត៌មានដែលផ្ដល់ឱ្យយើងដឹងថា ជើងទម្រ ឬបល្ល័ង្កនេះ ជាវត្ថុតម្កល់ប្រតិមាព្រះពុទ្ធអង្គដែលមានព្រះនាមថា "**ព្រះមុនីន្ទ្រ**" ដែលជាប្រតិមាស្ថាបនាឡើងដោយអ្នកប្រាជ្ញម្នាក់ឈ្មោះ "**វសុទេវ**" និងសប្បុរសជនជាច្រើនទៀត។ ម្យ៉ាងវិញទៀត សិលាចារឹកនេះ ក៏ជាប្រភពឱ្យយើងដឹងថា បុរាណដ្ឋានដែលសព្វថ្ងៃកំពុងបាក់បែកនេះ គឺពីមុនមកជាទេវស្ថានព្រះពុទ្ធសាសនាមហាយាន នៅស.វ. ទី១២។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ សកម្មភាពផ្តិតសិលាចារឹកនៅលើជើងទម្ររកឃើញនៅប្រាសាទកជ្រៃ ខេត្តបន្ទាយមានជ័យ



រូបលេខ២៖ សកម្មភាពផ្តិតសិលាចារឹកនៅលើជើងទម្ររកឃើញនៅប្រាសាទកជ្រៃ ខេត្តបន្ទាយមានជ័យ

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ៣៖ សំណៅផ្តិតសិលាចារឹកប្រាសាទកជ្រៃ (គែមខាងលើ ជ្រុងទី១)



រូបលេខ៤៖ សំណៅផ្តិតសិលាចារឹកប្រាសាទកជ្រៃ (គែមខាងលើ ជ្រុងទី២)

អត្ថបទដោយ៖ កំ វណ្ណារ៉ា



រូបលេខ២៥៖ សំណៅផ្តិតសិលាចារឹកប្រាសាទកជ្រៃ (ផ្នែកកណ្តាល ជ្រុងទី១)



រូបលេខ២៦៖ សំណៅផ្តិតសិលាចារឹកប្រាសាទកជ្រៃ (ផ្នែកកណ្តាល ជ្រុងទី២)

អត្ថបទដោយ៖ កំ វណ្ណារ៉ា